ពត៌មានប្រចាំថ្ងៃ
MOI DAILY NEWS
www.interior.gov.kh

# ពត៌មាន ប្រចាំថ្ងៃ របស់ក្រសួងមហាផ្ទៃ

## ថ្ងៃទី ២៨ ដល់ ២៩ ខែ មិថុនា ឆ្នាំ២០០៥

### តម្រួតថៃ ចាប់ប្រជាពលរដ្ឋខ្មែរដោយចោទប្រកាន់ពីបទមានថ្នាំញៀន

ខេត្តបន្ទាយមានជ័យ

- កាលពីថ្ងៃទី២៧/៦/២០០៥ វេលាម៉ោង ១៥:០០នាទី ប្រជាពលរដ្ឋខ្មែរឈ្មោះ ភឿន ភេទប្រុស អាយុ៣៧ឆ្នាំ បានឆ្លងដែនចូលក្នុងទឹកដីថៃ តាមច្រករបៀងក្នុង ភូមិសាស្ត្រភូមិក្បាលស្ពាន ហើយត្រូវបានតម្រួតថៃចាប់ខ្លួននៅត្រង់ចំណុចភូមិព្រី ឃុំថានទឹក ស្រុកអារ័ញ្ញ ខេត្តស្រះកែវ (ចម្ងាយ២០០០ម៉ែត្រ ពីព្រំដែនខ្មែរ-ថៃ) ដោយចោទប្រកាន់ពីបទមានថ្នាំញៀន យ៉ាម៉ាចំនួន ១៤០គ្រាប់ ។ ប្រជាពលរដ្ឋខ្មែររូបនេះត្រូវបានតម្រួតថៃបញ្ជូនទៅឃុំខ្លួននៅស្រុកអារ័ញ្ញ ។ ករណីនេះសមត្ថកិច្ចកំពុងទំនាក់ទំនងជាមួយភាគីថៃធ្វើការស្រាវជ្រាវបន្ត ។

### ការតវ៉ារបស់ប្រជាពលរដ្ឋ និងកម្មកររោងចក្រកាត់ដេរ

រាជធានីភ្នំពេញ

-នៅថ្ងៃទី២៧/៦/២០០៥ វេលាម៉ោង ១០:៣៥នាទី នៅរោងចក្រកាត់ដេរ **L & A** ទី១ មានកម្មករ ប្រមាណ១៥នាក់ បានរងជាតិពុល ដោយមានអាការ:ទន់ដៃ-ជើង និងសន្លប់បាត់ស្មារតី ។ ក្រុមហ៊ុន បានបញ្ជូនទៅព្យាបាលសង្គ្រោះនៅមន្ទីរពេទ្យ តែពុំបណ្តាលអោយមានគ្រោះថ្នាក់ដល់ជីវិតឡើយ ។ សមត្ថកិច្ចកំពុងធ្វើការស្រាវជ្រាវដើម្បីរកមូលហេតុនៃការរងជាតិពុលនេះ អោយបានច្បាស់លាស់ ។

-នាថ្ងៃទី២៨/៦/២០០៥ វេលាម៉ោង ១២:១៥នាទី មានប្រជាពលរដ្ឋប្រមាណ ៥០នាក់ (តំណាង អោយ៩៥គ្រួសារ) មកពីសង្កាត់សំរោងក្រោម ខណ្ឌដង្កោ បានមកប្រមូលផ្តុំគ្នានៅសួនច្បារមុខវត្ត បុទុមវត្តី គោលបំណងដាក់ពាក្យបណ្តឹងសុំអោយសម្តេចនាយករដ្ឋមន្ត្រីជួយអន្តរាគមន៍ដោះស្រាយបញ្ហា ឈ្មួញរំលោភយកដីស្រែ ៥៣ហិកតា របស់ពួកគាត់ ។ ការតវ៉ានេះត្រូវបាន តំណាងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ទទួលពាក្យបណ្តឹង និងសន្យាធ្វើការដោះស្រាយនៅមូលដ្ឋាន ។

ខេត្តកំពង់ស្ពឺ

-កាលពីថ្ងៃទី២៧/៦/២០០៥ វេលាម៉ោង ០៨:០០នាទី មានប្រជាពលរដ្ឋប្រមាណ ១៣០នាក់ តំណាងឱ្យ ១៧០គ្រួសារ មកពី ៩ភូមិ (ក្នុង ៣ឃុំ គឺ ឃុំភក្តី, ឃុំផុង, ឃុំកាត់ភ្លុក) ស្រុកបសេដ្ឋ ធ្វើការ តវ៉ាមិនអោយក្រុមហ៊ុនហ្គោលដឹនឡេន ឈូសឆាយដី នៅចំណុចត្រែទ័ព ក្នុងទឹកដីឃុំជាំសង្កែ ស្រុក ភ្នំស្រួច ព្រោះថាជាដីរបស់ពួកគាត់ចំនួន ៨០៥ហិកតា ។ ក្នុងការដោះស្រាយ ជាមួយ អាជ្ញាធរភូមិ ឃុំ-ស្រុក


អាស័យដ្ឋាន៖ បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារ:៨៥៥-២៣-៧២៦០៥២ Email:info@interior.gov.kh

អង្គការសិទ្ធមនុស្សវិធីខ្មែន និងស្ថាប័នពាក់ព័ន្ធ តំណាងប្រជាពលរដ្ឋបានសំណូមពរមួយចំនួនចំពោះដី និងដំណាំ ដែលប្រជាពលរដ្ឋបានរុករានកាន់កាប់កន្លងមកអាជ្ញាធរស្រុកភ្នំស្រួច បានដោះស្រាយទុកអោយប្រជាពលរដ្ឋ រឹងដីចំនួន ៨០៥ហិកតា ប្រជាជនត្រូវសុំអាជ្ញាធរស្រុកបសេដ្ឋជាអ្នកដោះ ស្រាយវិញ ។

## ពត៌មានសន្តិសុខសង្គម

រាជធានីភ្នំពេញ

-នៅថ្ងៃទី២៨/៦/២០០៥ វេលាម៉ោង ១១:៣០នាទី នៅភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ជនល្មើស ឈ្មោះ ឃាង ស៊ីឌឿង ភេទប្រុស អាយុ២៥ឆ្នាំ បានកាប់ទៅលើជនរងគ្រោះឈ្មោះ ផន វួច ភេទប្រុស អាយុ២៨ឆ្នាំ បណ្តាលអោយ របួសធ្ងន់ (មូលហេតុស្រវឹងស្រាទំនាស់ពាក្យសំដី) ជនល្មើស ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ។

-នាថ្ងៃដដែល វេលាម៉ោង ២១:៣០នាទី នៅចំណតរថយន្តផ្សារច្បារអំពៅ ខណ្ឌមានជ័យ ជនល្មើស ឈ្មោះ ស៊ុម ឡឹង ភេទប្រុស អាយុ៤២ឆ្នាំ បានវាយទៅលើជនរងគ្រោះឈ្មោះ ហុក ណាក់ ភេទប្រុស អាយុ៣៨ឆ្នាំ បណ្តាលអោយរបួសធ្ងន់ (មូលហេតុស្រវឹងស្រាទំនាស់ពាក្យសំដី) ជនល្មើស ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ។

ខេត្តកំពត

-នៅថ្ងៃទី២៧/៦/២០០៥ វេលាម៉ោង ១៩:០០នាទី មានជនល្មើស ០៣នាក់ ប្រដាប់ដោយពូថៅ-កាំបិត និងជំពាមកៅស៊ូ បានចូលប្លន់ផ្ទះប្រជាពលរដ្ឋឈ្មោះ ជួន ធីម ភេទប្រុស អាយុ៥៦ឆ្នាំ នៅភូមិ កណ្តាល ឃុំជម្ពូវ័ន្ត ស្រុកជុំគីរី ។ ក្នុងពេលធ្វើសកម្មភាព ពួកវាបានចាក់ម្ចាស់ផ្ទះបណ្តាលអោយរបួស រួចយកបានលុយ ១០០.០០០រៀល ។

ខេត្តកណ្តាល

- កាលពីយប់ថ្ងៃទី២៧/៦/២០០៥ នៅចំណុចក្បែរថ្នល់ជាតិលេខ១ ភូមិកណ្តាលក្រោម ឃុំបន្ទាយដែក ស្រុកកៀនស្វាយ មានករណីឃាតកម្ម ០១លើក បង្កដោយជនល្មើសមិនស្គាល់មុខ បានវាយជនរងគ្រោះឈ្មោះ ង្វៀន វ៉ាន់ហាយ ភេទប្រុស អាយុ៣៥ឆ្នាំ (ជនជាតិវៀតណាម) បណ្តាលអោយស្លាប់ ក្នុងខណៈពេលជនរងគ្រោះកំពុងចាក់កណ្តុរ ។ ករណីនេះ សមត្ថកិច្ចកំពុងធ្វើការ ស្រាវជ្រាវបន្ត ។

ខេត្តស្វាយរៀង

- កាលពីថ្ងៃទី២៧/៦/២០០៥ វេលាម៉ោង ១៨:០០នាទី នៅ ភុមិបុស ឃុំស្វាយតាយាន ស្រុកកំពង់រោទិ៍ មានករណី ឃាតកម្ម ០១លើក ជនល្មើសឈ្មោះ ឡេក រ៉ុន ភេទប្រុស អាយុ៤៨ឆ្នាំ បានកាប់ទៅលើជនរងគ្រោះឈ្មោះ ពេជ សាវ៉ាន់ ភេទប្រុស អាយុ២៩ឆ្នាំ បណ្តាលអោយស្លាប់នៅនឹងកន្លែង ។ (មូលហេតុទំនាស់) ជនល្មើសត្រូវបានសមត្ថកិច្ចឃាត់ខ្លួនកសាង សំណុំរឿងបញ្ជូន ទៅតុលាការ ។

ខេត្តកំពង់ចាម

-កាលពីថ្ងៃទី២៨/៦/២០០៥ វេលាម៉ោង ១៤:១០នាទី នៅក្នុងបរិវេណខាងមុខមន្ទីរសុខាភិបាលខេត្ត ឃុំ-ស្រុកកំពង់ចាម មានជនល្មើស ០១នាក់ បានប្លន់ និងវាយទៅលើជនរងគ្រោះ ០១នាក់ ភេទស្រី (មន្ត្រី សុខាភិបាលខេត្ត) បណ្តាលអោយរបួសស្រាល យកបានម៉ូតូជិះគេចខ្លួនបាត់ ។ ក្រោយកើតហេតុ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវរកឃើញ និងឃាត់ខ្លួនមុខសញ្ញាពាក់ព័ន្ធ ០១នាក់ ដកហូតបានអាវុធ AK ០១ដើម ម៉ូតូ០១គ្រឿង (របស់ជនរងគ្រោះ) ។



អាស័យដ្ឋាន៖ បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារ៖៨៥៥-២៣-៧២៦០៥២ Email:info@interior.gov.kh

ខេត្តកំពង់ធំ

-នៅថ្ងៃទី២៨/៦/២០០៥ វេលាម៉ោង ២៤:០០នាទីយប់ ក្នុងពិធីបុណ្យរាំកំសាន្ត នៅភូមិសង្គម ឃុំដីរីស្លាប់ ស្រុកកំពង់ស្វាយ មានករណីប៉ុនប៉ងធ្វើឃាត ០១ករណី បង្កដោយជនល្មើសមិនស្គាល់មុខ បានវាយទៅលើជនរងគ្រោះឈ្មោះ រ៉េត រ៉ូ ភេទប្រុស អាយុ១៨ឆ្នាំ បណ្តាលអោយរបួសធ្ងន់ រួច ជនល្មើសបានគេចខ្លួនបាត់ ។ ករណីនេះសមត្ថកិច្ចកំពុងធ្វើការស្រាវជ្រាវ ។

**គ្រោះថ្នាក់ផ្សេងៗ**

ខេត្តសៀមរាប

-នៅថ្ងៃទី២៧/៦/២០០៥ វេលាម៉ោង ១០:៣០នាទី នៅឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង មានគ្រោះថ្នាក់អគ្គីភ័យ បណ្តាលអោយឆេះរាលដាលអស់ផ្ទះប្រជាពលរដ្ឋចំនួន ២២៣ខ្នង ក្នុងនោះ ( នៅភូមិត្នោតកំបុត ១២១ខ្នង, ភូមិដីក្រហម ១០២ខ្នង) បណ្តាលអោយរបួសមនុស្ស ០១នាក់ និងខូចខាតទ្រព្យ សម្បត្តិមួយចំនួនធំ ( មូលហេតុបណ្តាលមកពីការធ្វេសប្រហែសភ្លើងចង្រ្កាន) ។

**លទ្ធផលកិច្ចប្រតិបត្តិការ**

រាជធានីភ្នំពេញ: កំលាំងសមត្ថកិច្ចបានបង្រ្កាបករណីប្លន់ប្រដាប់អាវុធ ០២ករណី ឃាត់ខ្លួន ០៤នាក់ ករណីលួច ០៣ករណី ករណីបង្ករបួសស្នាម ០៣ករណី  ឃាត់ខ្លួន ០៥នាក់, ករណីប្រើប្រាស់គ្រឿងញៀន០១ករណី អប់រំ០១នាក់ ករណីជួញដូរគ្រឿងញៀន ០១ករណី ឃាត់ខ្លួន០១នាក់, ករណីឆក់ ០១ករណី ឃាត់ខ្លួន ០៣នាក់, ករណីប៉ុនប៉ងរំលោភ ០១ករណី ឃាត់ខ្លួន០១នាក់ ។

ខេត្តកំពង់ចាម :  កំលាំងសមត្ថកិច្ចបានបង្រ្កាបករណី មនុស្សឃាត ០១ករណី ឃាត់ខ្លួន០១នាក់ ករណីប្លន់ប្រដាប់អាវុធ ០១ករណី ឃាត់ខ្លួន០១នាក់ ។

ខេត្តកណ្តាល:  កំលាំងសមត្ថកិច្ចបានបង្រ្កាបករណី បង្ករបួសស្នាម ០១ករណី ឃាត់ខ្លួន០១នាក់, ករណីលួចប្រជារាស្រ្ត ០១ករណី ឃាត់ខ្លួន ០១នាក់ ។

ខេត្តស្វាយរៀង :  កំលាំងសមត្ថកិច្ចបានបង្រ្កាបករណី ឃាតកម្ម ០១ករណី ឃាត់ខ្លួន០១នាក់ ។

ក្រុងប៉ៃលិន : កំលាំងសមត្ថកិច្ចបានបង្រ្កាបករណី រំលោភសម្លាប់ ០១ករណី ឃាត់ខ្លួន០១នាក់ ។

ខេត្តកោះកុង : កំលាំងសមត្ថកិច្ចបានបង្រ្កាបករណី ប្រើប្រាស់អាវុធខុសច្បាប់ ០១ករណី  ឃាត់ខ្លួន០១នាក់ ដកហូតអាវុធ **AK** ០១ដើម ។

(  ប្រភពព័ត៌មានពីអគ្គស្នងការដ្ឋាននគរបាលជាតិ  )



អាស័យដ្ឋាន :  បន្ទប់លេខ១១៤  អគារទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារ :៨៥៥-២៣-៧២៦០៥២  Email:info@interior.gov.kh